ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៦៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាសហប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ (**គ.ក.ប.យ.**)។

## ជំពូកទី២
## តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន គ.ក.ប.យ.

**មាត្រា២ .-**

អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងការងារបច្ចេកទេសរបស់ **គ.ក.ប.យ.**
- សិក្សា ស្រាវជ្រាវ និងរៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីដាក់ជូន **គ.ក.ប.យ.** ពិនិត្យ និងសម្រេច

- សហការ សម្របសម្រួល និងផ្តល់ការគាំទ្រនិងជំនួយបច្ចេកទេសតាមការចាំបាច់ ដល់ក្រសួង ស្ថាប័ន និងអង្គភាពនានាពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌ តាមការចង្អុលបង្ហាញរបស់ **គ.ក.ប.យ.**
- រៀបចំសេចក្តីព្រាងប្រព័ន្ធលើកទឹកចិត្ត ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព ក្នុងការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំសេចក្តីព្រាងសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីដាក់ជូន **គ.ក.ប.យ.** ពិនិត្យ និងសម្រេច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ផ្តល់យោបល់ និងលើកសំណើដំណោះស្រាយជូន **គ.ក.ប.យ.** លើបញ្ហាប្រឈម និងបញ្ហាបច្ចេកទេសនានា ដើម្បីជំរុញល្បឿន និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ និងអន្តរជាតិ លើការងារពាក់ព័ន្ធនឹងការកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ជូន **គ.ក.ប.យ.**
- រៀបចំចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីសមិទ្ធផលនានានៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដំណើរការការងាររបស់ **គ.ក.ប.យ.** និងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **គ.ក.ប.យ.**
- អនុវត្តភារកិច្ចផ្សេងទៀតដែល **គ.ក.ប.យ.** ប្រគល់ឱ្យ។

## ជំពូកទី៣

## រចនាសម្ព័ន្ធចំណុះអគ្គលេខាធិការដ្ឋាន គ.ក.ប.យ.

**មាត្រា៣** ._

អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** មានរចនាសម្ព័ន្ធ ដូចខាងក្រោម៖

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានកិច្ចការកែទម្រង់
- នាយកដ្ឋានកិច្ចសហប្រតិបត្តិការ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ ..**

នាយកដ្ឋានកិច្ចការទូទៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់ **គ.ក.ប.យ**.
- សម្របសម្រួលសកម្មភាពគ្រប់គ្រងផ្នែករដ្ឋបាល និងប្រព័ន្ធព័ត៌មានវិទ្យារបស់ **គ.ក.ប.យ**.
- សម្របសម្រួលការងារទំនាក់ទំនងសាធារណៈ និងកិច្ចការនាំពាក្យ
- គ្រប់គ្រងចលនវត្ថុ អចលនវត្ថុ និងធ្វើបញ្ជីសារពើភណ្ឌរបស់ **គ.ក.ប.យ**.
- សម្របសម្រួលស្នើសុំថវិកា និងធ្វើរបាយការណ៍ទូទាត់ចំណូល-ចំណាយថវិកាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ **គ.ក.ប.យ**.
- បង្កើត រៀបចំ និងគ្រប់គ្រងបណ្តាញទំនាក់ទំនងសង្គមផ្សេងៗរបស់ **គ.ក.ប.យ**.
- គ្រប់គ្រងឯកសាររដ្ឋបាល និងការងារតម្កល់ឯកសាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ**. និងរបស់ **គ.ក.ប.យ**.
- ធ្វើការផ្សព្វផ្សាយនូវសមិទ្ធផលការងាររបស់ **គ.ក.ប.យ**. ដល់សាធារណជន
- សម្របសម្រួលរៀបចំកិច្ចប្រជុំ និងកម្មវិធីផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ**. និងរបស់ **គ.ក.ប.យ**.
- រៀបចំផែនការសកម្មភាព និងកម្មវិធីការងាររបស់អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ**. និងរបស់ **គ.ក.ប.យ**.
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិការបស់ **គ.ក.ប.យ**.
- បូកសរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពនានារបស់អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ**. និងរបស់ **គ.ក.ប.យ**.
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ**. ប្រគល់ឱ្យ។

**មាត្រា៥ ..**

នាយកដ្ឋានកិច្ចការកែទម្រង់ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- សិក្សា និងរៀបចំគម្រោងផ្សេងៗបម្រើឱ្យការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំ ចងក្រង និងបោះពុម្ពផ្សាយនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារនានាពាក់ព័ន្ធនឹងការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដោយសហការជាមួយនាយកដ្ឋានកិច្ចការទូទៅ

- ចូលរួមរៀបចំផែនការសកម្មភាព និងកម្មវិធីការងាររបស់អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** និងរបស់ **គ.ក.ប.យ.**
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិការបស់ **គ.ក.ប.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ប្រគល់ឱ្យ។

**មាត្រា៦** .-

នាយកដ្ឋានកិច្ចសហប្រតិបត្តិការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួលកិច្ចការបរទេស និងកិច្ចការទំនាក់ទំនងអន្តរជាតិ
- រៀបចំផែនការសកម្មភាព ដើម្បីពង្រឹង និងលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ និងអន្តរជាតិក្នុងកិច្ចការកែទម្រង់ប្រព័ន្ធយុត្តិធម៌
- សម្របសម្រួល កៀរគរ និងគ្រប់គ្រងជំនួយជាតិ និងអន្តរជាតិ ដើម្បីគាំទ្រ និងលើកកម្ពស់ប្រសិទ្ធភាពការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- សិក្សា និងរៀបចំបង្កើតគម្រោងផ្សេងៗបម្រើឱ្យការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍ ដោយសហការជាមួយនាយកដ្ឋានកិច្ចការកែទម្រង់
- គ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍
- សម្របសម្រួល និងរៀបចំបេសកកម្មទៅក្រៅប្រទេសរបស់ថ្នាក់ដឹកនាំ និងគណៈប្រតិភូរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** និងរបស់ **គ.ក.ប.យ.**
- រៀបចំកម្មវិធីសហប្រតិបត្តិការ អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងៗពាក់ព័ន្ធនឹងការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដោយសហការជាមួយនាយកដ្ឋានកិច្ចការកែទម្រង់
- ចូលរួមរៀបចំផែនការសកម្មភាព និងកម្មវិធីការងាររបស់អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** និងរបស់ **គ.ក.ប.យ.**
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិការបស់ **គ.ក.ប.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ប្រគល់ឱ្យ។

**មាត្រា៧** .-

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួន ដើម្បីបំពេញមុខងាររបស់ខ្លួន តាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ នៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាសហប្រធាន **គ.ក.ប.យ.**។

**មាត្រា៨** .-

ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** និងក្រុមការងារដែលចូលរួមក្នុងការអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ទទួលបានប្រាក់ឧបត្ថម្ភ និងការលើកទឹកចិត្តផ្សេងៗ ផ្អែកលើសមិទ្ធកម្ម ដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល ដូចមានចែងក្នុងមាត្រា៨ នៃព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌។

# ជំពូកទី៤
# អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**និងជាសហប្រធានគណៈកម្មាធិការកែទម្រង់ប្រព័ន្ធយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០២៤
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

**អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ក.ប.យ.**

